# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអភិវឌ្ឍន៍ជនបទ




# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ
# ឆ្នាំ២០១៩-២០២៣

**ខែមករា ឆ្នាំ២០១៩**

# អារម្ភកថា

លទ្ធផលនៃការងារអភិវឌ្ឍន៍ជនបទ ដែលបានមកពីការអនុវត្តដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៤-២០១៨ បានឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋជនបទ ជាអាទិ៍ ការងារហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ការងារផ្គត់ផ្គង់ទឹកស្អាត របៀបរស់នៅស្អាត អនាម័យជនបទ ព្រមទាំងវិស័យដទៃទៀត និងបានរួមចំណែកកាត់បន្ថយភាពក្រីក្រជាង ១% ក្នុង១ឆ្នាំ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរង្វង់ ៧% ក្នុង១ឆ្នាំ។

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ដែលជារបៀបវារៈអភិវឌ្ឍ សង្គម សេដ្ឋកិច្ចកម្ពុជា និងឆ្លងតាមបទពិសោធន៍ដ៏សំបូរបែបក្នុងរយៈពេលកន្លងមកនោះ ក្រសួងអភិវឌ្ឍន៍ជនបទបន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ សម្រាប់ជាផែនទីបង្ហាញផ្លូវ ក្នុងការអនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយតាមតួនាទី និងភារកិច្ចរបស់ខ្លួន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទនេះ នឹងផ្តោតលើកម្មវិធីសំខាន់ៗចំនួន ៤ រួមមាន (១) ការពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស (២) ការស្ថាបនា ជួសជុល និងលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសាធារណៈ (៣) ការលើកកម្ពស់សុខភាព ការអប់រំ លក្ខខណ្ឌនៃការរស់នៅ និង (៤) ការបង្កើតការងារ មុខរបរ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ច។

ជាមួយនឹងធាតុចេញជាវិជ្ជមាន ដែលនាំទៅដល់លទ្ធផលចុងក្រោយគួរជាទីមោទនៈ ក្រសួងក៏នៅជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដែលត្រូវដោះស្រាយបន្ត ដូចជាការធ្វើឲ្យមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍប្រកបដោយសមធម៌នៅតំបន់ជនបទដាច់ស្រយាល បានបណ្តុះបណ្តាលវិជ្ជាជីវៈជាមូលដ្ឋានសម្រាប់ការបង្កើតការងារថ្មីៗបន្ថែម ការងារសមភាពយេនឌ័រ និងការងារសម្រាប់ជនជាតិដើមភាគតិចជាដើម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ នេះ មានគោលបំណងផ្តល់នូវការតម្រង់ទិសដល់មន្ត្រីគ្រប់លំដាប់ថ្នាក់នៃក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជាក្រសួងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់ ព្រមទាំងអ្នកទទួលផល ដើម្បីរួមគ្នាគាំទ្រ ចូលរួមចំណែក និងសហប្រតិបត្តិការអនុវត្តឲ្យទទួលបានជោគជ័យតាមការគ្រោងទុក។

ក្រសួងអភិវឌ្ឍន៍ជនបទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាល ចំពោះក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ អ្នកទទួលផល និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមឧបត្ថម្ភ គាំទ្រទាំងស្មារតី សម្ភារៈ បច្ចេកទេស និងថវិកា ដើម្បីប្រែក្លាយផែនការយុទ្ធសាស្ត្រនេះឲ្យទៅជាសមិទ្ធផលជាក់ស្តែង សម្រាប់ជាគុណប្រយោជន៍របស់ប្រជាជនជនបទ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ នឹងចូលរួមសហការ អនុវត្ត ផែនការយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព ឈានទៅសម្រេចបានជោគជ័យតាមគោលដៅកំណត់។

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

# មាតិកា


១សេចក្តីផ្តើម ..................................................... ១

២នៃរដ្ឋសភា សមិទ្ធិផលសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទនីតិកាលទី៥ .................... ២

៣. ទិសដៅនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩២០២៣-............................ ៦

៤. ក្របខ័ណ្ឌយុទ្ធសាស្រ្ត..................................................... ៧

៥អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ .១. .................................................... ៩

៥កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ.២............................................ ៩

៥ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ .៣.................................................................. ១១

៥ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ.៤. ........................................................ ១២

៦. ធនធានហិរញ្ញវត្ថុ..................................................... ១៣

៧. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ..................................................... ១៣

៨. សេចក្តីសន្និដ្ឋាន..................................................... ១៥

# ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់លើគ្រប់វិស័យទាំងវិស័យសេដ្ឋកិច្ច វិស័យសង្គមកិច្ច និងវប្បធម៌ ដែលបានប្រែក្លាយពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ កម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ ដែលសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ព្រមទាំងជាប្រទេសជាប់ចំណាត់ថ្នាក់ទី១ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការលម្អសូចនាករផ្នែកសង្គមកិច្ច។

ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៤-២០១៨ ដោយបាននាំមកនូវភាពប្រែប្រួលជាវិជ្ជមានអំពីស្ថានភាពជីវភាពរស់នៅ សុខភាព អនាម័យ និងសេវាសាធារណៈផ្សេងៗ ដោយសុខដុមរម្យនាក្នុងសង្គមគ្រួសារនៅតំបន់ជនបទ ។ សកម្មភាពជាច្រើនដែលក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តរួមមាន (១) ការស្តាបនាផ្លូវថ្មី ស្ពានបេតុង លូមូល លូជ្រុងគ្រប់ប្រភេទ ជួសជុលថែទាំផ្លូវជនបទជាលក្ខណៈខួប និងប្រចាំ កែលម្អកម្រាលផ្លូវពីក្រួសក្រហមទៅជាផ្លូវកៅស៊ូពីរជាន់ ស្តារឡើងវិញផ្លូវជនបទដែលខូចខាតដោយទឹកជំនន់ សាងសង់ទីទួលសុវត្ថិភាពសម្រាប់បង្ការគ្រោះមហន្តរាយដោយទឹកជំនន់។ (២) ការផ្គត់ផ្គង់ទឹកស្អាត អប់រំសុខភាព អនាម័យ ក្នុងការលើកកម្ពស់លក្ខខណ្ឌការរស់នៅរបស់ប្រជាជនជនបទឲ្យបានល្អប្រសើរ ដើម្បីឈានទៅសម្រេចបាននូវទស្សនវិស័យរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ថា "**ឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅសហគមន៍ជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ និងរស់នៅក្នុង បរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព**"។ (៣) ផ្តល់ជូនការងារ មុខរបរអាជីវកម្មសហគ្រាសខ្នាតតូច និងសកម្មភាពសេដ្ឋកិច្ចជាច្រើនទៀត ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌជីវិតរបស់ប្រជាជនជនបទឲ្យបានកាន់តែល្អប្រសើរជាងមុន ។ ក្រសួងបានអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍ជនបទចម្រុះជាច្រើនវិស័យការងារដូចជា បង្កើតសិប្បកម្ម សហគ្រាសខ្នាតតូចមធ្យម ការងារកសិកម្ម សុខាភិបាល បរិស្ថាន អបរំ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន ការងារឥណទាន និងវិស័យការងារដទៃទៀតក្នុងគោលដៅជំរុញការអភិវឌ្ឍជនបទប្រកបដោយសក្តានុពល និងនវានុវត្តន៍។

ទោះបីជាក្រសួងសម្រេចបានជោគជ័យជាច្រើន ក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៤-២០១៨ ក៏ដោយក៏នៅមានបញ្ហាមួយចំនួន ពុំទាន់ដោះស្រាយអស់នៅឡើយដូចជា ការកើនឡើងយ៉ាងគំហុកនូវតម្រូវការប្រើប្រាស់ផ្លូវជនបទ ការដឹកជញ្ជូនលើសទម្ងន់ដែលច្បាប់កំណត់ ការអភិវឌ្ឍនៅទីជាច់ស្រយាល ការកើនឡើងនៃការធ្វើចំណាកស្រុកស្វែងរកការងារ ចំណេះជំនាញមូលដ្ឋាននៅពុំទាន់គ្រប់គ្រាន់ ការយល់

ដឹងពីបញ្ហារស់នៅស្អាត សុខភាពអនាម័យនៅខ្វះចន្លោះជាច្រើន ពិសេសនៅតំបន់ជនបទដាច់ស្រយាល។ កត្តាប្រែប្រួលអាកាសធាតុនៅតែជាបញ្ហាប្រឈមមួយផងដែរសម្រាប់ហេដ្ឋារចនា សម្ព័ន្ធផ្លូវថ្នល់ជនបទ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត។ ប្រភពហិរញ្ញប្បទានសម្រាប់យកទៅអភិវឌ្ឍនៅមានកម្រិតនៅឡើយ ហើយការចូលរួមរបស់ស្ត្រីក្នុងការងារអភិវឌ្ឍន៍ក៏ទាមទារឲ្យមានការជំរុញ និងយកចិត្តទុកដាក់បន្ថែមទៀត។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញជាក្របខណ្ឌយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ២០១៩-២០២៣ ដើម្បីបន្តលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទ មានជាអាទិ៍៖ **ទី១.អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍** បន្ថែមទៀតដល់គ្រប់ច្រកល្ហកនៃតំបន់ជនបទ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ។ **ទី២.កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ** សំដៅធ្វើឲ្យប្រសើរឡើងនូវគុណភាពការរស់នៅប្រកបដោយផាសុខភាព ហូបស្អាត ភូមិឃុំមានបរិស្ថានរស់នៅស្អាត ភូមិឃុំមានសុវត្ថិភាព គឺជាផ្នែកមួយជួយជំរុញឲ្យមានលក្ខខណ្ឌនៃរបៀបរស់នៅបែបទំនើបនៅតំបន់ជនបទ។ **ទី៣.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ** ក្នុងន័យជំរុញបង្កើតការងារ មុខរបរ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ចឲ្យមានរូបភាពចម្រុះដោយគិតតាំងពីរបរកសិកម្ម និងមិនមែនកសិកម្មនៅតាមសហគមន៍ជនបទ ក្នុងការចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ បង្កើនប្រាក់ចំណូលគ្រួសារដែលជាកត្តាសំខាន់បំផុតពុំអាចខ្វះបាននៅតាមគ្រួសារនីមួយៗនៅជនបទ។ **ទី៤. ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ** ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន គាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិបាលកិច្ចល្អ ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីចូលរួមចំណែក ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់ដទៃទៀតឲ្យកាន់តែមានប្រសិទ្ធភាព ខ្ពស់។

## ២. សមិទ្ធិផលសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទនីតិកាលទី៥ នៃរដ្ឋសភា

សមិទ្ធផលសំខាន់ៗ ដែលក្រសួងសម្រេចបានក្នុងនីតិកាលទី ៥ នៃរដ្ឋសភាមានដូចតទៅ៖

### ២.១ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

ការពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ ក្រសួងបានដាក់ចេញនូវគោលនយោបាយស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស សំដៅបង្កើនសមត្ថភាពមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីរួមចំណែកក្នុងការអនុវត្តន៍កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ដើម្បីពន្លឿនការអភិវឌ្ឍន៍ និងធានាប្រសិទ្ធភាពនៃការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋ ក្រសួងអភិវឌ្ឍន៍ជនបទ មានកម្មវិធីបណ្តុះបណ្តាលពីរប្រភេទគឺ៖ បណ្តុះបណ្តាលមន្ត្រីរាជការ

ក្រសួង និងបណ្តុះបណ្តាលជំនាញជូនប្រជាពលរដ្ឋដើម្បីបង្កើតមុខរបរបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ជំរុញកំណើនសេដ្ឋកិច្ចជនបទ។

រយៈពេល ៥ឆ្នាំកន្លងទៅនេះ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីសរុបចំនួន ១៦ ៦៦៨នាក់ ក្នុងនោះការបណ្តុះបណ្តាលជំនាញផ្សេងៗក្នុងប្រទេសបានចំនួន ១៥ ៨៤៤នាក់ ក្រៅប្រទេសបានចំនួន ២៨៤នាក់។ ក្រសួងបានធ្វើការបណ្តុះបណ្តាលជំនាញកុំព្យូទ័ររដ្ឋបាលបាន ៨២៤នាក់។ មន្ត្រីរាជការចំនួន ២ ៥០០នាក់ ត្រូវបានទទួលការបណ្តុះបណ្តាលការកសាងផែនការយុទ្ធសាស្ត្រថវិកា សវនកម្ម នីតិវិធីលទ្ធកម្ម និងការងារហិរញ្ញវត្ថុ។

## ២.២ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍

ផ្លូវជនបទបាលចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការធ្វើសមាហរណកម្មរវាងតំបន់ជនបទ និងទីប្រជុំជន។ ការស្តាបនា ការជួសជុល និងលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គមនាគមន៍ និងសេវាសាធារណៈ បាននឹងកំពុងនាំមកនូវកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាពជូនដល់ប្រជាជនគ្រប់ទិសទីនៅទូទាំងប្រទេស ជាពិសេសតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងអភិវឌ្ឍន៍ជនបទ បាននឹងកំពុងធ្វើការកែលម្អផ្លូវជនបទ ពីផ្លូវដីទៅជាផ្លូវក្រាលក្រួសក្រហម ពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ និងផ្លូវក្រាលបេតុង ដើម្បីបង្កភាពងាយស្រួលក្នុងការធ្វើដំណើរ កាត់បន្ថយពេលវេលា និងការចំណាយលើការដឹកជញ្ជូនកសិផល និងទំនិញជូនដល់ប្រជាជននៅតំបន់ជនបទ។

សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- សាងសង់ផ្លូវថ្មីក្រាលក្រួសក្រហមចំនួន ២ ២៧៨គ.ម
- ជួសជុល ថែទាំផ្លូវក្រួសក្រហមជាលក្ខណៈខួប និងប្រចាំបានចំនួន ៨ ៦២០គ.ម
- ស្តារឡើងវិញផ្លូវជនបទដែលខូចខាត ដោយទឹកជំនន់បានប្រវែង ៥១១គ.ម
- កែលម្អកម្រាលផ្លូវពីក្រួសក្រហមទៅជាផ្លូវកៅស៊ូពីរជាន់ បានចំនួន ១ ៦៥០គ.ម
- សាងសង់លូមូល លូជ្រុងគ្រប់ប្រភេទបានចំនួន ៤ ២៧២កន្លែង សាងសង់ស្ពានបេតុង និងសំណង់បង្ហៀរទឹកសរុបចំនួន ១៩៩កន្លែង
- ដាំកូនឈើអមសងខាងផ្លូវការពារទប់ទល់នឹងការប្រែប្រួលអាកាសធាតុបានចំនួន ២១៧ ២៩២ដើម
- សាងសង់ទីទួលសុវត្ថិភាពសម្រាប់បង្ការគ្រោះមហន្តរាយដោយទឹកជំនន់បាន ៣កន្លែង និងសាងសង់អគារមជ្ឈមណ្ឌល សម្រាប់ប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គ្រោះបន្ទាន់បានចំនួន ២អគារ

## ២.៣ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

សម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាត ការរស់នៅស្អាត និងអនាម័យជនបទ រាជរដ្ឋាភិបាលបានកំណត់ទិសដៅរបស់ខ្លួនដើម្បីធ្វើឲ្យប្រជាជននៅជនបទទទួលបាននូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ១០០% នៅឆ្នាំ ២០២៥ ដូចមានចែងក្នុងទស្សនវិស័យនៃគោលនយោបាយ ដែលបានកំណត់ថា " *ឆ្នាំ២០២៥ប្រជាពលរដ្ឋនៅជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព* " ។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានរៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទឆ្នាំ ២០១៤ - ២០២៥ ក្នុងគោលបំណងធ្វើឲ្យសេវាទឹកស្អាត សុខភាព និងអនាម័យនៅជនបទមានភាពប្រសើរឡើង និងប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ ។ រាជរដ្ឋាភិបាលបានកំណត់ទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥ ស្តីពីការផ្គត់ផ្គង់ទឹកស្អាតជនបទឲ្យបាន ៥០% និងអនាម័យឲ្យបាន ៣០% នៅឆ្នាំ ២០១៥។ ជាក់ស្តែង យើងសម្រេចបាន ៥៣% សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និង ៥២.៩% សម្រាប់អនាម័យ លើសគោលដៅដែលបានគ្រោងទុក។ បន្ទាប់ពីបានកំណត់ទិសដៅថ្មី ៦០% ទាំងការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ជនបទនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ២០១៤-២០១៨ យើងក៏នៅតែអាចសម្រេចលើសគោលដៅក្នុងឆ្នាំ ២០១៨ ទៀតដោយយោងតាមទិន្នន័យអង្កេត សេដ្ឋកិច្ចសង្គមចុងក្រោយឆ្នាំ ២០១៦ អត្រាគ្របដណ្តប់ការផ្គត់ផ្គង់ទឹកស្អាតជនបទបានកើនដល់ ៥៣.៩% និងអនាម័យជនបទបានកើនដល់ ៦៧.៤% រួចទៅហើយ។ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖

- សាងសង់អណ្តូងទឹកបានចំនួន ៤ ១១៥អណ្តូង
- ជួសជុលអណ្តូងគ្រប់ប្រភេទដែលខូចឲ្យដំណើរការឡើងវិញបានចំនួន ៥ ២៣៧អណ្តូង
- សាងសង់ស្រះទឹកបានចំនួន ១ ៨៩៨ស្រះ
- សាងសង់អាងត្រងទឹកភ្លៀងចំណុះ ៣-៥ម៉ែត្រគូប បានចំនួន ៩៨២អាង
- ចែកពាងត្រងទឹកភ្លៀងដល់ប្រជាពលរដ្ឋតាមគ្រួសារបានចំនួន ១៣៧ ៣៤៣ពាង
- សាងសង់ប្រព័ន្ធចែកចាយទឹកតាមទុយោផ្លាស្ទីក(PVC) តាមភូមិបានចំនួន ៤៤៣ប្រព័ន្ធ
- សាងសង់ធុងចម្រោះទឹកស្អាតធ្វើពីបេតុងចំណុះ ២០លីត្រ សម្រាប់បរិភោគតាមគ្រួសារបានចំនួន ៧៦ ៣៤៦ធុង
- ជួសជុលស្ពារទំនប់ ប្រឡាយជារាសាស្ត្រខ្នាតតូចបានចំនួន ៤៩គ.ម
- ប្រជាពលរដ្ឋទទួលបានសេវាប្រើប្រាស់ទឹកស្អាតមានចំនួនសរុប ២ ៩០៦ ៣២៦នាក់
- សាងសង់បង្គន់អនាម័យជនបទបានចំនួន ១០២ ៧១៤បង្គន់
- សាងសង់កន្លែងលាងដៃតាមសាលារៀនបានចំនួន ៥៥កន្លែង
- សាងសង់ឡដុតសម្រាមបានចំនួន ២៦កន្លែង។

នៅឆ្នាំ២០០០ កន្លងទៅនេះ ប្រទេសកម្ពុជា ជាប្រទេសដែលទទួលបានចំណាត់ថ្នាក់លេខ២នៅក្នុងពិភពលោកដែលបានកាត់បន្ថយចំនួនអត្រាភាគរយអ្នកបន្ទោរបង់ពាសវាលពាសកាល ៨២,៧% មកត្រឹម ៤០,៦% នៅឆ្នាំ២០១៥។ លទ្ធផលជាវិជ្ជមាននេះ បានមកដោយសារ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល គួបផ្សំនឹងការចូលរួមសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជា មួយដៃគូអភិវឌ្ឍនានា អង្គការមិនមែនរដ្ឋាភិបាលក្រៅប្រទេស និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេស និងអ្នកពាក់ព័ន្ធផ្សេងៗទៀតរួមទាំងវិស័យឯកជនផងដែរ។

## ២.៤ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

ការបង្កើតការងារ មុខរបរ សហគ្រិនភាពនិងសកម្មភាពសេដ្ឋកិច្ច ជាផ្នែកមួយដ៏សំខាន់ដើម្បីលើកកម្ពស់សុខភាព ការអប់រំ លក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជននៅជនបទ។ ក្រសួងបានជំរុញលើកកម្ពស់សេដ្ឋកិច្ចជនបទ ក្នុងសហគមន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជាក្នុងរូបភាពជាការអភិវឌ្ឍន៍ចម្រុះជាច្រើនវិស័យដូចជា សិប្បកម្ម សហគ្រិនខ្នាតតូច មធ្យម កសិកម្ម សុខាភិបាល បរិស្ថាន បណ្តុះបណ្តាល ឥណទាន និងវិស័យដទៃទៀត ក្នុងគោលដៅជំរុញការអភិវឌ្ឍជនបទឲ្យមាននិរន្តភាព និងបង្កើតបានសុខដុមរមនាក្នុងសង្គមគ្រួសារនៅជនបទដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ។ ការអភិវឌ្ឍន៍ជនបទចម្រុះ គឺជាវិធានមួយដែលជានាប្រសិទ្ធភាពខ្ពស់នៅក្នុងវិស័យអភិវឌ្ឍន៍ជនបទកម្ពុជា ដែលមានការចូលរួមពីគ្រប់ផ្នែកទាំងអស់ដើម្បីបំពេញឲ្យគ្នាទៅវិញទៅមក ក្នុងការដោះស្រាយរាល់បញ្ហារួមដែលកើតមានឡើងនៅតាមតំបន់ជនបទ។ ក្រសួងក៏បានយកចិត្តទុកដាក់អភិវឌ្ឍតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅឲ្យមានការរីកចម្រើន ខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយជួយពួកគេឲ្យមានសិទ្ធិពេញលេញក្នុងការចូលរួមការធ្វើសេចក្តីសម្រេចនានា ការកសាងគោលនយោបាយជាតិ ការការពារដោយច្បាប់ និងមានវិធានការសង្គម ដើម្បីទទួលបាននូវសេចក្តីត្រូវការចាំបាច់សម្រាប់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ប្រពៃណី ភាសា និងអត្តសញ្ញាណ វប្បធម៌ទំនៀមទម្លាប់ជនជាតិដើមភាគតិច។

រយៈពេល ៥ឆ្នាំកន្លងមកនេះ ក្រសួងបានបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបានចំនួន ២៦ ៤៨៥ភូមិ។ ក្រសួងក៏បានផ្តល់វគ្គបណ្តុះបណ្តាលដូចជាស្តារប្រឡាយទឹក ជួសជុលផ្លូវក្នុងភូមិ បង្កើតច្បារបន្លែក្នុងភូមិ ការចិញ្ចឹមសត្វពាហនៈជាលក្ខណៈគ្រួសារ ចិញ្ចឹមមាន់ ទាលក្ខណៈគ្រួសារ ចិញ្ចឹមត្រីជាគ្រួសារ ផ្តល់ជំនាញសិប្បកម្ម កសិកម្ម សេវាកម្ម រោងជីកំប៉ុស្តិ៍ ។ល។ បានចំនួនសរុប ២២៧ភូមិ។ ក្រសួងបានផ្តល់ប្រឹក្សាជួយបង្កើត ការងារជូនប្រជាពលរដ្ឋពីការធ្វើអាជីវកម្មខ្នាតតូច ការងារកសិកម្មចម្រុះបាន ៦៨ ៤៧៦នាក់ បង្កើតក្រុមសន្សំនៅតាមសហគមន៍ដើម្បីទទួលសេវាឥណទានជនបទបានចំនួន ៤ ៧២៥នាក់ វគ្គបណ្តុះបណ្តាលជំនាញបង្កើតការងារថ្មីជូនប្រជាពលរដ្ឋដូចជា៖ តម្បាញហូល ក្រមា មេជាងចង្ក្រានជីវឧស្ម័ន សិប្បកម្មផលិតសាប៊ូ ដែលមានអ្នកចូលរួម ៥៣៧នាក់។ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូចចំនួន ១៩លើក មានអ្នកចូលរួម ៨២នាក់ និងបណ្តុះ

បណ្តាលគ្រូបង្គោលស្តីពីការបញ្ជ្រាបការយល់ដឹងពីគ្រោះមហន្តរាយដោយធម្មជាតិបាន ២២៧វគ្គ មានប្រជាពលរដ្ឋចូលរួមចំនួន ៩ ០៧៤នាក់។ បានរៀបចំសិក្ខាសាលាស្តីពី ជំងឺអេដស៍ កាមរោគ និងសុខភាពបន្តពូជ ដែលមានប្រជាពលរដ្ឋជនបទចំនួន ៤៤៩នាក់។ ចំពោះការបណ្តុះ បណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាននៅតាមសហគមន៍ជនបទ ក្រសួងបានបង្កើតមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមូលដ្ឋានចំនួន៨ខេត្តគឺៈ ខេត្តស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កំពង់ចាម បាត់ដំបង ពោធិ៍សាត់ និងកំពត ដែលបានវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗរួមមាន ៖ ជំនាញកាត់ដេរ ជួសជុលកុំព្យូទ័រ ជួសជុលម៉ាស៊ីនដេរ គ្រឿងយន្តកសិកម្ម ធ្វើសង្ហារឹម អ៊ុតសក់ កាត់សក់ ។ល។ សរុបបានចំនួន ៤០ ៣៣០នាក់ ដែលបច្ចុប្បន្នប្រជាពលរដ្ឋដែលបានទទួលការបណ្តុះបណ្តាលកំពុងប្រកបអាជីវកម្មនៅតាមសហគមន៍ជនបទ ទីប្រជុំជន និងមួយចំនួនបានមកធ្វើការនៅភ្នំពេញដោយទទួលបានប្រាក់ខែខ្ពស់ជាងប្រជាជនដែលគ្មានជំនាញ ។

សម្រាប់ការអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ក្រសួងបានវាយតម្លៃ និងកំណត់អត្តសញ្ញាណជនជាតដើមភាគតិចបានចំនួន ៥៤សហគមន៍ និងពង្រឹងសមត្ថភាព ជនជាតិដើមភាគតិចបានចំនួន ៣៥០នាក់។ ជារៀងរាល់ឆ្នាំ ក្រសួងបានប្រារព្ធទិវាជនជាតិដើមភាគតិចដែលមានជនជាតិដើមភាគតិចចូលរួមបានចំនួន ៦ ០០០នាក់ ផ្តល់សម្ភារៈសិក្សាដល់សិស្សក្រីក្រនៅជនបទបានចំនួន ៩២ ៦៥៤នាក់ ដើម្បីចូលរួមបង្កើនគុណភាពសិក្សារបស់សិស្សពិសេសសិស្សក្រីក្រ ព្រមទាំងសាងសង់ភូមិថ្មីបានចំនួន ៩ភូមិ សាងសង់ផ្ទះជូនគ្រួសារក្រីក្របានចំនួន ១៤២ខ្នង និងសាងសង់សាលារៀន មជ្ឈមណ្ឌល អគារស្នាក់នៅរបស់សិស្សសរុបបានចំនួន ៩២ខ្នង។

## ៣. ទិសដៅនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ២០១៩ - ២០២៣ នេះ មានគោលបំណងផ្តល់នូវការតម្រង់ទិសដល់មន្ត្រីគ្រប់លំដាប់ថ្នាក់នៃក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជាក្រសួងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់ ព្រមទាំងអ្នកទទួលផល ដើម្បីរួមគ្នាគាំទ្រ ចូលរួមចំណែក និងសហប្រតិបត្តិការអនុវត្តផែនការយុទ្ធសាស្រ្តនេះឲ្យទទួលបានជោគជ័យតាមការគ្រោងទុក។

ទិសដៅចម្បងនៃផែនការយុទ្ធសាស្រ្តនេះ ដើម្បីលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ទិសដៅសំខាន់ៗនៃផែនការយុទ្ធសាស្រ្តមានដូចតទៅៈ

- ជំរុញ និងលើកទឹកចិត្តមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទឲ្យទទួលបានការបណ្តុះបណ្តាលជំនាញដល់ ៨០ម៉ោងក្នុងមួយឆ្នាំសម្រាប់មន្ត្រីម្នាក់ៗ
- ស្តាបនាឲ្យបានផ្លូវជនបទប្រវែង១ ០០០គ.ម និងផ្លូវចាក់កៅស៊ូប្រវែង ៥៥០គម
- ថែទាំ ជួសជុល កែលម្អផ្លូវជនបទប្រវែងឲ្យបានប្រវែង ១២ ០០០គ.ម
- សម្រេចឲ្យបាននូវគោលដៅរួម ៩០% នៃការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់

អនាម័យជនបទនៅឆ្នាំ២០២៣

- ជំរុញខេត្តយ៉ាងតិចចំនួន ០៥ ឈានទៅឈប់បន្ទោរបង់ពាសវាលពាសកាល
- បង្កើតមុខរបរ និងការងារឲ្យបាន ១ ៥០០នាក់ ជូនប្រជាជនជនបទដើម្បីលើកកម្ពស់លក្ខខណ្ឌជីវិតរស់នៅបានល្អប្រសើរ
- បង្កើនការផ្ទេរមុខងារវិមជ្ឈការ និងវិសហមជ្ឈការ ៥០ស្រុក បន្ថែមទៀត
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចំនួន ១០កន្លែង
- សាងសង់ទីទួលសុវត្ថិភាពការពារគ្រោះធម្មជាតិបន្ថែមចំនួន ២០កន្លែង
- ធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ៥០០ភូមិ
- កំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចឲ្យបាន ២០០សហគមន៍
- បន្តចូលរួមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ និងទី៤ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ក្រសួងអភិវឌ្ឍន៍ជនបទបានសម្រេចដោយជោគជ័យ នូវការអនុវត្តន៍ផែនការអភិវឌ្ឍន៍ជនបទឆ្នាំ២០១៤-២០១៨ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងស្ថាប័ន ដោយបានជំរុញឲ្យលក្ខខណ្ឌជីវិតរស់នៅរបស់ប្រជាជនជនបទមានការប្រែប្រួលជាវិជ្ជមានព្រមៗគ្នា ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ជនបទ ទាំងការផ្តល់សេវាទឹកស្អាត និងអនាម័យជនបទ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍។

ជនជាតិដើមភាគតិច ត្រូវបានកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច និងបណ្តុះបណ្តាលជំនាញបង្កើតការងារជូនជនជាតិដើមភាគតិច កែទម្លាប់មិនល្អរបស់ពួកគាត់ក្នុងការធ្វើកសិកម្ម។ ប្រជាជនជនបទ ពិសេសជនងាយ រងគ្រោះ ត្រូវបានក្រសួងយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញ បង្កើតការងារ ស្វែងរកទីផ្សារ និងសង់ផ្សារសហគមន៍ដើម្បីជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់គាត់។

ជាមួយនឹងការរីកចម្រើនគួរកត់សម្គាល់លើគ្រប់វិស័យនៅតាមតំបន់ជនបទ ក្រសួងអភិវឌ្ឍន៍ជនបទក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជាការកើនឡើងនូវតម្រូវការរបស់ប្រជាពលរដ្ឋនៅជនបទ ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍នៅទីដាច់ស្រយាល យេនឌ័រ និងជនជាតិដើមភាគតិចជាដើម។

ការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គមនៅជនបទបានធ្វើឲ្យទំហំនៃសេចក្តីត្រូវការរបស់ប្រជាជនជនបទមានការកើនឡើងផងដែរ ដែលទាមទារឲ្យមានការវិនិយោគកាន់តែច្រើនបន្ថែមទៀតដើម្បីឆ្លើយតបនឹងតម្រូវការទាំងនោះ ជាពិសេស ការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចនៅតាមតំបន់ជនបទ បានធ្វើឲ្យផ្លូវជនបទមួយចំនួនឆាប់ខូចទៅវិញ ដោយការដឹកលើសទម្ងន់។

កត្តាប្រែប្រួលអាកាសធាតុក៏ជាបញ្ហាប្រឈមមួយផងដែរ លើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជនបទ និងហេដ្ឋា រចនាសម្ព័ន្ធរូបវន្តដទៃទៀត។ ថវិកាសម្រាប់យកទៅអភិវឌ្ឍនៅជនបទនៅមានកម្រិតនៅឡើយសម្រាប់ការស្ថាបនា សាងសង់ផ្លូវថ្នល់ជនបទដែលមានប្រវែងជាង ៤៥ ២០០គ.ម ដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់ប្រជាជនជនបទនៅទូទាំងប្រទេស ជាពិសេសនៅតំបន់ដាច់ស្រយាល។ ការចូលរួមរបស់ស្ត្រីក្នុងការងារអភិវឌ្ឍន៍ក៏ទាមទារឲ្យមានការជំរុញ និងយកចិត្តទុកដាក់បន្ថែមទៀត។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញជាក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជនជនបទឡើងវិញតាមរយៈ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ ដោយជំរុញបង្កើនការស្ថាបនា ជួសជុល និងលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសាធារណៈបន្ថែមទៀតដល់គ្រប់ច្រកល្ហកនៃតំបន់ជនបទ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់។

ការអប់រំលើកកម្ពស់សុខភាព អនាម័យ ធ្វើឲ្យប្រជាជនយល់ដឹងពីការរស់នៅស្អាត ផឹកស្អាត ភូមិឃុំមានបរិស្ថានរស់នៅស្អាត ភូមិឃុំមានសុវត្ថិភាព គឺជាផ្នែកមួយជំរុញឲ្យមានលក្ខខណ្ឌនៃរបៀបរស់នៅបែបស៊ីវិល័យនៅជនបទ។ ការដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃជាកត្តាសំខាន់បំផុតដែលពុំអាចខ្វះបាន ហេតុនេះ ក្រសួងបានកំណត់យុទ្ធសាស្ត្របង្កើតការងារ មុខរបរ សហគ្រិនភាព ដើម្បីជំរុញឲ្យកើតមានឡើងសកម្មភាពសេដ្ឋកិច្ចនៅគ្រប់ទីកន្លែងនៅតាមនិគមតាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន បណ្តុះគំនិត និងបំផុសឲ្យប្រជាពលរដ្ឋជនបទ ចូលរួមយ៉ាងសកម្មក្នុងចលនានេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តជាកម្ចីដែលមានអត្រាការប្រាក់ទាបធ្វើជាទុនបង្កើតមុខរបរថ្មី និងចលនាឲ្យប្រជាពលរដ្ឋគាំទ្រផលិតផលក្នុងស្រុក ដើម្បីចូលរួមលើកទឹកចិត្តដល់ផលិតផលរបស់ខ្មែរយើង។

ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់ទិសដៅជាយុទ្ធសាស្ត្រជាអាទិភាពចំនួន០៤ ដើម្បីធានាលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទឲ្យបានកាន់តែល្អប្រសើរ ដោយបង្កើនលក្ខខណ្ឌជីវិតរស់នៅរបស់ប្រជាជនជនបទ តាមរយៈការផ្តល់សេវាសាធារណៈផ្សេងៗនៅជនបទដូចជាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជនបទ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ការអប់រំសុខភាព និងបង្កើតការងារ មុខរបរ និងសហគ្រិនភាពនៅតាមគ្រួសារក្នុងសហគមន៍ជនបទ។

ដើម្បីសម្រេចបានទិសដៅជាយុទ្ធសាស្ត្រខាងលើ និងស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌយុទ្ធសាស្ត្រថវិកាកែទម្រង់ថវិកាឆ្នាំ២០១៨-២០២៥ ក្រសួងអភិវឌ្ឍន៍ជនបទបានប្រែក្លាយយុទ្ធសាស្ត្រទាំង ០៤ នេះជាកម្មវិធីសម្រាប់អនុវត្តជាក់ស្តែងក្នុងនីតិកាលទី៦ នៃរដ្ឋសភា ដូចខាងក្រោម៖

កម្មវិធីទី១ ៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍
កម្មវិធីទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ
កម្មវិធីទី៣ ៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ
កម្មវិធីទី៤ ៖ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

## ៥. សកម្មភាពការងារ

ដើម្បីអនុវត្តយុទ្ធសាស្ត្រអាទិភាពទាំង០៤ ខាងលើ ក្រសួងមានផែនការសកម្មភាពជាច្រើន ដូចខាងក្រោម៖

### ៥.១. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍

ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទ ក្រសួងនឹងបន្តស្តាបនាផ្លូវជនបទ និងកែលម្អផ្លូវជនបទឲ្យទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ និងផ្លូវបេតុងដែលអាចធន់នឹងការដឹកធ្ងន់ និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងវប្បធម៌នៅតាមជនបទ។ សកម្មភាពការងារជាអាទិភាពមានដូចតទៅ៖

- បន្តបង្កើន និងជំរុញការផ្តល់អាទិភាពខ្ពស់ដល់ការស្តាបនា ការស្តារ ការកែលម្អផ្លូវជនបទជាជំហានៗពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ និងផ្លូវបេតុង ការថែទាំផ្លូវជនបទ និងជួសជុលជាប់ជាប្រចាំ ដើម្បីធានាការប្រើប្រាស់បានគ្រប់រដូវកាលនិងធន់នឹងការប្រែប្រួលអាកាសធាតុ
- បន្តរៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទដោយមានការចូលរួមពីសហគមន៍មូលដ្ឋានជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់
- បន្តផ្តល់ជំនួយបច្ចេកទេស ដល់ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ក្នុងការស្តារ ជួសជុល និងធ្វើឲ្យប្រសើរឡើងនូវផ្លូវជនបទ
- បន្តពង្រីកកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ការថែទាំផ្លូវជាលក្ខណៈប្រចាំដល់ថ្នាក់ក្រោមជាតិ
- សាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដូចជាប្រឡាយស្រោចស្រព ទំនប់ទឹក ស្ពាន សំណង់ស្ទាក់ទឹក និងសំណង់សិល្បការ្យផ្សេងៗ
- បន្តអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទនៃព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដែលអាចមានលទ្ធភាពក្នុងកសាងផែនការកំណត់អាទិភាពខ្សែផ្លូវ និងកសាងផែនការថវិកាសម្រាប់ការងារស្តាបនា ជួសជុល និងថែទាំផ្លូវជនបទ

### ៥.២.កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

ដើម្បីធានាលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាពលរដ្ឋជនបទឲ្យបានល្អប្រសើរ ក្រសួងអភិវឌ្ឍន៍ជនបទបានសម្រួចទិសដៅរបស់ខ្លួន ដើម្បីសម្រេចឲ្យបាននូវ

ទស្សនវិស័យនៃគោលនយោបាយដែលបានកំណត់ថា " ឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព"។ ដើម្បីឈានទៅសម្រេចបាននូវទស្សនវិស័យនេះក្រសួង បានកំណត់យកទិសដៅរយៈពេលមធ្យមនូវអត្រាគ្របដណ្ដប់៩០% ទាំងទឹកស្អាត និងអនាម័យនៅឆ្នាំ២០២៣ នៅក្នុងផែនការសកម្មភាពជាតិជំហ៊ានទី២ របស់ខ្លួន។ ក្រសួងបានផ្ដោតការយកចិត្តទុកដាក់លើវិធានការ ៣ សំខាន់ៗស្ដីពីការប្រើប្រាស់បង្គន់ ការលាងសម្អាតដៃនឹងសាប៊ូ និងការបរិភោគទឹកស្អាត ។ សកម្មភាពជាអាទិភាពដូចខាងក្រោមៈ

- សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទដទៃទៀតដូចជា ស្រះទឹក អណ្តូងទឹក ប្រព័ន្ធចែកចាយទឹកតាមទុយោខ្នាតតូចសហគមន៍ អាងដំកល់ទឹក ពាងយក្ស អាងត្រងទឹកភ្លៀង ធុងចម្រោះ បង្គន់អនាម័យ ។ល។
- ធ្វើការត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តន៍ផែនការសកម្មភាពជាតិស្ដីពី ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅជំហានទី១ ឆ្នាំ២០១៤-២០១៨ និងរៀបចំផែនការសកម្មភាពជាតិស្ដីពីការលើសកំពស់ការផ្គត់ផ្គង់ទឹកស្អាត សុខភាព និងការលើកកំពស់ អនាម័យនៅជនបទជំហានទី២ ឆ្នាំ២០១៩-២០២៣
- ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យលទ្ធផល ពង្រឹងសមត្ថភាពស្ថាប័ន កៀរគរធនធាន និងបន្តពង្រឹងកិច្ចសហការរវាងដៃគូពាក់ព័ន្ធទាំងអស់ ជានាឲ្យបាននូវសុខដុមនីយកម្ម កម្មវិធី និងគម្រោងទាំងអស់ឲ្យស្របតាមផែនការសកម្មភាពជាតិ បន្តបង្កើន និងជំរុញការអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត សុខភាព និងអនាម័យសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនប្រកបដោយគុណភាព និងប្រសិទ្ធភាព
- ពង្រីកសកម្មភាពការផ្គត់ផ្គង់ទឹកស្អាត សុខភាព និងការលើកកម្ពស់អនាម័យជនបទ
- បន្តអប់រំផ្សព្វផ្សាយដល់ប្រជាជនជនបទឲ្យយល់ដឹងពីបរិស្ថាន និងប្រតិបត្តិអនាម័យ
- ពង្រីកការតបណ្តាញទឹកស្អាតទទួលទាន នៅសហគមន៍ជនបទ
- លុបបំបាត់ការបន្ទោបង់ពាសវាលពាសកាលដោយពង្រីកពីភូមិទៅឃុំ ពីឃុំទៅស្រុក ពីស្រុកទៅខេត្ត
- យ៉ាងហោចណាស់ខេត្តចំនួន ៥ នឹងបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល
- ជំរុញការផ្លាស់ប្តូរទម្លាប់នៃការប្រើប្រាស់បង្គន់ ការលាងដៃនឹងសាប៊ូ និងការបរិភោគទឹកស្អាត។
- ផ្សព្វផ្សាយ និងពង្រឹងយន្តការអនុវត្តគោលនយោបាយជាតិស្ដីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ
- ផ្សព្វផ្សាយ និងពង្រឹងយន្តការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទ

- ផ្សព្វផ្សាយ និងពង្រឹងយន្តការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត សុខភាព និងការលើកកម្ពស់អនាម័យជនបទលើកទី២។

## ៥.៣. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

ក្រសួងនឹងបន្តជំរុញ និងបង្កើនល្បឿនផលិតកម្មសេដ្ឋកិច្ចជនបទ និងសហគ្រិនភាព ដើម្បីគាំទ្រដល់ការបង្កើនប្រាក់ចំណូលតាមគ្រួសារ ដោយធ្វើឲ្យគ្រួសារនៅជនបទមានជីវភាពល្អប្រសើរឡើងតាមរយៈការផ្តល់ចំណេះជំនាញ បង្កើតការងារ ផ្តល់ឥណទានសមស្រប រកទីផ្សារ និងបង្កើតបរិយាកាសធុរៈកិច្ចឲ្យបានល្អប្រសើរ បង្កើនស្ថិរភាពប្រាក់ចំណូលតាមគ្រួសារនីមួយៗ ដើម្បីចូលរួមទប់ស្កាត់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ សកម្មភាពជាអាទិភាពរួមមាន៖

- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចល័តនៅទីប្រជុំជនស្រុក ឬឃុំ
- ចលនាប្រជាជនឲ្យចូលរួមទទួលយកការបណ្តុះបណ្តាលជំនាញមូលដ្ឋាន
- ជំរុញឲ្យប្រជាជនក្នុងសហគមន៍ចូលរួមកម្មវិធីបង្កើតអាជីវកម្មខ្នាតតូចនិងខ្នាតគ្រួសារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលមុខវិជ្ជាទៅតាមតម្រូវការនៅតាមតំបន់នីមួយៗ
- ផ្តល់ជំនាញដល់ជនជាតិដើមភាគតិចក្នុងសហគមន៍ដែលពួកគេរស់នៅ
- ជំរុញបង្កើតទីផ្សារសហគមន៍ តាំងបង្ហាញផលិតផល
- ជំរុញឲ្យប្រជាពលរដ្ឋខ្មែរគាំទ្រ និងប្រើប្រាស់ផលិតផលខ្មែរ
- ជួសជុល និងសាងសង់ផ្សារជនបទដើម្បីដោះដូរផលិតផលក្នុងស្រុក
- បន្តបណ្តុះបណ្តាលស្ត្រីមេផ្ទះ ក្នុងការថែរក្សាទុក និងការកែច្នៃម្ហូបអាហារ និងការរៀបចំសួនដំណាំរបស់គ្រួសារ សម្រាប់បំពេញតម្រូវការ និងបង្កើនប្រាក់ចំណូលគ្រួសារ
- ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋជនបទដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពីមជ្ឈមណ្ឌលក្នុងការបង្កើតមុខរបរសមស្រប
- ជំរុញការផ្តល់សេវាប្រាក់កម្ចីដែលមានអត្រាការប្រាក់សមរម្យ សម្រាប់ការអភិវឌ្ឍន៍សិប្បកម្ម មុខជំនួញ សហគ្រាសខ្នាតតូច និងមធ្យម ជាមួយនឹងការផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើតមុខរបរ បង្កើតការច្នៃប្រឌិតបង្កើតផលិតផលថ្មី ព្រមទាំងការខិតខំពង្រីកទីផ្សារដើម្បីដំណើរអាជីវកម្មក្នុងសហគមន៍
- បន្តគាំទ្រដល់ការបង្កើតធនាគារមិនមែនសាច់ប្រាក់ដូចជា ធនាគារស្រូវ ធនាគារមាន់ ធនាគារជី។ល។
- បន្តកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច
- រៀបចំប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកប្រចាំឆ្នាំ១៥ខេត្តគោលដៅ
- បង្កើតមជ្ឈមណ្ឌលអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- បន្តជំរុញការអភិវឌ្ឍន៍នៅតាមតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឲ្យកាន់តែមានការរីកចម្រើន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិទទួលបាននូវការការពារដោយច្បាប់ និងវិធានការសង្គមនានា ដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការរស់នៅប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ ប្រពៃណី និងភាសារបស់បងប្អូនជនជាតិដើមភាគតិច
- បន្តអនុវត្តគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច សារាចរណែនាំ នីតិវិធីនៃការកំណត់អត្តសញ្ញាណ និងចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច។

## ៥.៤.ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

ក្រសួងនឹងបន្តជំរុញការកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័នដោយបន្តការបណ្តុះបណ្តាលដល់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យមានសមត្ថភាពកាន់តែប្រសើរឡើងបន្ថែមទៀតក្នុងការផ្តល់សេវាសាធារណៈ កាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការងារ វិស័យអភិវឌ្ឍន៍ជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទបន្តចូលរួមកម្មវិធីកំណែទម្រង់ផ្សេងៗរបស់ រាជរដ្ឋាភិបាលដូចជា កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ និងទី៤ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងដីធ្លីនិងកំណែទម្រង់កងទ័ព ព្រមទាំងកំណែទម្រង់ផ្សេងៗទៀតដើម្បីធានាការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងដំណើរឆ្ពោះទៅកាន់របៀបវារៈទស្សនៈ វិស័យ ២០៣០។

- ពង្រឹងយន្តការរៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល ផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ
- ពង្រឹងយន្តការប្រើប្រាស់ និងគ្រប់គ្រងថវិកាតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា
- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក
- ពង្រឹងយន្តការគ្រប់គ្រង និងការបណ្តុះបណ្តាលឲ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់
- បង្កើនការគាំទ្រហិរញ្ញវត្ថុសម្រាប់ការងារអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- ជំរុញ និងលើកទឹកចិត្តមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទឲ្យទទួលបានការបណ្តុះបណ្តាលជំនាញយ៉ាងតិច ៨០ម៉ោងក្នុងមួយឆ្នាំ
- ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តន៍គោលនយោបាយស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស
- ចូលរួមគាំទ្រយ៉ាងសកម្មដល់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងទី៤
- ជំរុញពង្រីកស្រុកគោលដៅក្នុងការផ្ទេរមុខងារវិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់ដទៃទៀត

## ៦. ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ បានមកពីថវិកាជាតិ ថវិកាហិរញ្ញប្បទានសម្បទាន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងសប្បុរសជន រួមគ្នាសម្រាប់គាំទ្រវិស័យអភិវឌ្ឍន៍ជនបទរយៈពេល៥ឆ្នាំ ២០១៩-២០២៣ ដែលមានទឹកប្រាក់សរុបប្រមាណ **២ ២៦៥ ០៥៨ ០៨៧ដុល្លាអាមេរិក** ដែលគិតជាមធ្យមប្រមាណ ៤៥៣លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ក្នុងនោះរាជរដ្ឋាភិបាលចំណាយប្រហែលជិត ១០០លានដុល្លា អង្គការមិនមែនរដ្ឋាភិបាលប្រមាណ ៦៨លានដុល្លា ក្រៅពីនេះជាថវិកាបន្ថែមបានមកពីហិរញ្ញប្បទានសម្បទានជាកម្ចី និងជំនួយឥតសំណងពីបណ្តាប្រទេសជាមិត្តរបស់ព្រះរាជាណាចក្រកម្ពុជា។

**តារាងវិភាគថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣**

| តម្រូវការថវិកាប្រចាំឆ្នាំ | ឯកតា | ២០១៨ ចាប់ផ្តើម | ២០១៩ ប៉ាន់ស្មាន | ២០២០ ប៉ាន់ស្មាន | ២០២១ ប៉ាន់ស្មាន | ២០២២ ប៉ាន់ស្មាន | ២០២៣ ប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|
| ថវិកាជាតិ | លានរៀល | 339,137.00 | 373,294.5 | 447,953.4 | 537,544.08 | 645,052.89 | 774,063.50 |
| | ដុល្លា | 84,784,250 | 93,323,625 | 111,988,350 | 134,386,020 | 161,263,224 | 193,515,868 |
| ថវិកាអង្គការមិនមែនរដ្ឋាភិបាល | ដុល្លា | 68,695,900 | 68,500,000 | 68,500,000 | 68,500,000 | 68,500,000 | 68,500,000 |
| គម្រោងថវិកាហិរញ្ញប្បទានសហប្រត្តិការ | ដុល្លា | 113,289,200 | 154,095,900 | 96,181,200 | 48,033,900 | 50,570,000 | 55,168,000 |
| គម្រោងវិនិយោគសាធារណៈលើការងារអភិវឌ្ឍន៍ជនបទ | ដុល្លា | 34,870,200 | 200,847,800 | 192,883,000 | 130,301,200 | 150,000,000 | 150.000,000 |
| **សរុប** | ដុល្លា | **301,639,550** | **516,767,325** | **469,552,550** | **381,221,120** | **430,333,224** | **467,183,868** |

## ៧. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ផែនការយុទ្ធសាស្ត្រនឹងត្រូវបានត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងចុងក្រោយប្រសិនបើមានការចាំបាច់។ ការវាយតម្លៃនឹងផ្តោតយកចិត្តទុកដាក់លើលទ្ធផលចុងក្រោយនៃការអនុវត្តន៍យុទ្ធសាស្ត្រទាំង០៤ គឺៈ (១)អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ (២) កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ (៣) ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ (៤) ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ សម្រាប់អនុវត្តក្នុងនីតិកាលទី៦ នៃរដ្ឋសភាជាតិតាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។ ការតាមដាន ត្រួតពិនិត្យ តាមដាន និងវាយតម្លៃនឹងត្រូវបានពិនិត្យប្រចាំឆ្នាំ។

## តារាងតាមដានសូចនាករការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣

| សូចនាករ | ២០១៨ ចាប់ផ្តើម | ២០១៩ ព្យាករណ៍ | ២០២០ ព្យាករណ៍ | ២០២១ ព្យាករណ៍ | ២០២២ ព្យាករណ៍ | ២០២៣ ព្យាករណ៍ |
|---|---|---|---|---|---|---|
| ការស្តារ និងសាងសង់ផ្លូវជនបទ (លើប្រវែងផ្លូវសរុប ៤៥,២០០គ.ម) | 29,242.42គ.ម | 30,860គ.ម | 33,079គ.ម | 36,180គ.ម | 39,816គ.ម | 43,818គ.ម |
| កែលម្អផ្លូវជនបទទៅជាកៅស៊ូពីជាន់ ឬបេតុងដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុ (គ.ម) | 100គ.ម | 120គ.ម | 144គ.ម | 172គ.ម | 207គ.ម | 248គ.ម |
| ថែទាំផ្លូវជាលក្ខណៈខួបនិងប្រចាំ (គ.ម) | 7,457.33គ.ម | 8,948គ.ម | 10,738គ.ម | 12,886គ.ម | 15,463គ.ម | 18,556គ.ម |
| ភាគរយប្រជាជន ជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តភាព (%) | 58% (2017) | 67% | 72% | 78% | 84% | 90% |
| ភាគរយប្រជាជន ជនបទទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តភាព (%) | 71%(2017) | 78% | 81% | 84% | 87% | 90% |
| ខេត្តដែលបានបញ្ឈប់បន្ទោបង់ពាសវាលពាសកាល (ODF) | 0 | 1ខេត្ត | 2ខេត្ត | 3ខេត្ត | 4ខេត្ត | 5ខេត្ត |
| មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចល័ត (មណ្ឌល) | 0 | 5មណ្ឌល | 10មណ្ឌល | 15មណ្ឌល | 20មណ្ឌល | 25មណ្ឌល |
| ចំនួនប្រជាពលរដ្ឋដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន | 4,313នាក់ | 7,000នាក់ | 10,000នាក់ | 15,000នាក់ | 25,000នាក់ | 35,000នាក់ |
| ចំនួនគ្រួសារដែលបានបង្កើតសហគ្រាសខ្នាតតូចថ្មីក្រោយបានទទួលការបណ្តុះបណ្តាលជំនាញមូលដ្ឋាន | ពុំមានទិន្នន័យ | 150គ្រួសារ | 250គ្រួសារ | 350គ្រួសារ | 450គ្រួសារ | 550គ្រួសារ |
| មន្ត្រីរាជការក្រសួងដែលទទួលបានការពង្រឹងសមត្ថភាព ដល់៨០ម៉ោងក្នុងមួយឆ្នាំៗក្នុងម្នាក់ៗ | 42ម៉ោង/ម្នាក់ | 45 ម៉ោង/ម្នាក់ | 50ម៉ោង/ម្នាក់ | 60ម៉ោង/ម្នាក់ | 70ម៉ោង/ម្នាក់ | 80ម៉ោង/ម្នាក់ |
| ចំនួនសហគមន៍បានទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ | 143 សហគមន៍ | 153សហគមន៍ | 163 សហគមន៍ | 173សហគមន៍ | 183 សហគមន៍ | 200 សហគមន៍ |

## ៨. សេចក្តីសន្និដ្ឋាន

ឈរលើមូលដ្ឋានសុខសន្តិភាពពេញបរិបូរណ៍ និងដោយមានការគាំទ្រពីរាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា ក្រសួងអភិវឌ្ឍន៍ជនបទរួមជាមួយអង្គភាពក្រោមឱវាទដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនបានអនុវត្តដោយប្រសិទ្ធភាពនូវតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីបម្រើសេវាសាធារណៈជូនប្រជាជននៅជនបទទូទាំងប្រទេសរួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និងការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ ដើម្បីចូលរួមចំណែកធ្វើឲ្យសេដ្ឋកិច្ចគ្រួសាររបស់ប្រជាជននៅជនបទ មានការអភិវឌ្ឍន៍ និងឈានទៅអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស ។ ដើម្បីឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះទទួលបានជោគជ័យ គឺត្រូវទាមទារឲ្យមានការគាំទ្រ និងការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ផ្នែកឯកជន និងសហគមន៍ផងដែរ៕